# ការចុះបញ្ជីដីធ្លី


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ**

លេខ :

| | | | |
|---|---|---|---|
| ខេត្ត ក្រុង : | | សន្លឹកផែនទីលេខ : | |
| ស្រុក ខណ្ឌ : | | លេខក្បាលដី : | |
| ឃុំ សង្កាត់ : | | ទំហំ : | |
| ភូមិ : | | ប្រភេទដី : | |
| | | លក្ខណៈនៃការប្រើប្រាស់ដី : | ឯកជន |



មាត្រដ្ឋាន 1/500

ឧបត្ថម្ភដោយ

ផលិតដោយ

ដៃគូអនុវត្តគម្រោង

# ការចុះបញ្ជីដី មានលក្ខណៈដាច់ដោយដុំ

## ដំណាក់កាលទី១៖ អំពីការដាក់ពាក្យស្នើសុំចុះបញ្ជីដី

អ្នកកាន់កាប់ដីត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដីទៅរដ្ឋបាលសុរិយោដីថ្នាក់ស្រុក ខណ្ឌ តាមរយៈមេឃុំ ឬចៅសង្កាត់ដែលក្បាលដីនោះស្ថិតនៅ ហើយពាក្យស្នើសុំត្រូវពិនិត្យដោយរដ្ឋបាលសុរិយោដី ស្រុក ខណ្ឌ។ ពាក្យស្នើសុំត្រូវធ្វើជាពីរច្បាប់ និងអាចមានឯកសារណាបផ្សេងៗភ្ជាប់មកជាមួយដូចជាកស្តុតាងទាក់ទងនឹងក្បាលដី ឬឯកសារសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី។

*( មាត្រា ៧,៨ នៃអនុក្រឹត្យស្តីពីការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ )*




(CC) CCHR 2017

## ដំណាក់កាលទី២៖ អំពីកិច្ចប្រតិបត្តិការបច្ចេកទេស

**១.អំពីការងារវាល** អភិបាលស្រុក ខណ្ឌត្រូវផ្សព្វផ្សាយជាសាធារណៈអំពីកាលបរិច្ឆេទនៃការកំណត់ព្រំដី និងវាស់វែងយ៉ាងហោចណាស់ ១៤ ថ្ងៃ មុនកាលបរិច្ឆេទ ដើម្បីឱ្យបុគ្គលពាក់ព័ន្ធធ្វើការត្រួតពិនិត្យ ឬតវ៉ា។

**២. ការងារនៅការិយាល័យ** បន្ទាប់មក ក្រុមមន្ត្រីចុះបញ្ជីដីធ្លីធ្វើការកំណត់ព្រំដី វាស់វែងក្បាលដី និងធ្វើការវិនិច្ឆ័យទៅលើឯកសារ និងភស្តុតាងផ្សេងៗ និងត្រូវរៀបចំប្លង់សុរិយោដី។

*(មាត្រា ៩,១០,១១,១២ នៃអនុក្រឹត្យស្តីពីការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ )*

## ដំណាក់កាលទី៣៖ អំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ

រដ្ឋបាលសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្សព្វផ្សាយឯកសារនៃការវិនិច្ឆ័យនោះជាសាធារណៈរយៈពេល៣០ ថ្ងៃ នៅសាលាស្រុក ខណ្ឌ ដែលមានសមត្ថកិច្ច។ សេចក្តីថតចម្លងនៃឯកសារទាំងនេះក៏ត្រូវបិទផ្សាយផងដែរ នៅទីស្នាក់ការឃុំសង្កាត់ ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ។ ក្នុងករណីមិនមានការជំទាស់ ឬការតវ៉ាក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈទិន្នន័យដែលបានកត់ត្រាក្នុងឯកសារបិទផ្សាយនោះត្រូវបានចាត់ទុកជាទិន្នន័យសុក្រឹតដែលអាចកំណត់យកជាផ្លូវការតាមច្បាប់បាន។

*(មាត្រា ១៣ នៃអនុក្រឹត្យស្តីពីការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ )*






## ដំណាក់កាលទី៤៖ អំពីការសម្រេចលើឯកសារ

ក្រោយពីផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈ មន្ត្រីជំនាញត្រូវធ្វើរបាយការណ៍ដាក់ជូនរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ពិនិត្យ និងចុះហត្ថលេខាបញ្ជូនសំណុំរឿងទាំងមូលទៅរដ្ឋបាលសុរិយោដីខេត្ត ក្រុង ។

*(មាត្រា ១៣, ១៤,១៦ នៃអនុក្រឹត្យស្តីពីការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ )*














## ដំណាក់កាលទី៥៖ អំពីការចេញប័ណ្ណដី

ប្រសិនបើឯកសារត្រឹមត្រូវហើយ រដ្ឋបាលសុរិយោដី ថ្នាក់ខេត្ត ក្រុងនឹងបញ្ជូនសំណុំរឿងទៅរដ្ឋបាលសុរិយោដីថ្នាក់កណ្តាល ដើម្បីធ្វើការចុះបញ្ជី និងចេញប័ណ្ណកម្មសិទ្ធិជូនដល់ម្ចាស់ដី ។

*(មាត្រា ១៦, ១៨ នៃអនុក្រឹត្យស្តីពីការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ )*



# ការចុះបញ្ជីដីធ្លី

ខិត្តប័ណ្ណស្តីពីការចុះបញ្ជីដីធ្លីដែលផលិតឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាមានគោលបំណងផ្តល់ព័ត៌មានបន្ថែមដល់អ្នកកាន់កាប់ដីស្របច្បាប់ដែលមានបំណងចង់ទទួលបានប័ណ្ណកម្មសិទ្ធិ។ ខិត្តប័ណ្ណនេះ បង្ហាញពីដំណើរការនៃការចុះបញ្ជីដីធ្លីនៅកម្ពុជា និងពន្យល់អំពីដំណើរការនីមួយៗ នៃការចុះបញ្ជីដីធ្លីព្រមទាំងមានរូបភាពបញ្ជាក់ពីដំណាក់កាលទាំងនេះផងដែរ។ ដំណើរការចុះបញ្ជីដីធ្លីត្រូវបានបែងចែកជាពីរប្រភេទគឺការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។

## ទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

តាមរយៈ ៖ ផ្ទះលេខ ៧៩៨ ផ្លូវ៩៩ ប្រអប់សំបុត្រ ១៥០៦ សង្កាត់បឹងត្របែក

ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរសព្ទ ៖ (+៨៥៥) ២៣ ៧២៦ ៩០១

អ៊ីម៉ែល ៖ info@cchrcambodia.org

cc BY NC SA